# ដំណើរការទូទៅ
# នៃការផ្ទេរមុខងារ និងធនធានឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ



# មាតិកា

I. សេចក្តីផ្តើម

II. អនុក្រឹត្យ ស្តីពីដំណើរការទូទៅនៃការផ្ទេរមុខងារ និង ធនធានឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាត

## I. សេចក្តីផ្តើម

### ១. ភាពចាំបាច់នៃការផ្ទេរមុខងារ និងធនធានឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ

- បង្កិតសេវាឲ្យទៅជិតកៀកប្រជាពលរដ្ឋ
- កែលំអគុណភាពការផ្តល់សេវាដល់ប្រជាពលរដ្ឋ
- មានតម្លាភាព និងមានគណនេយ្យភាព
- បង្កើនការចូលរួមរបស់ប្រជាពលរដ្ឋ
- សមាសធាតុសំខាន់មួយ ដែលបានកំណត់ក្នុងកម្មវិធីជាតិ និង ផែនការអនុវត្តរយៈពេលបីឆ្នាំដំបូង( ផអ៣ )នៃកម្មវិធីជាតិនិង



## ២. មូលដ្ឋានគោលនយោបាយ និងច្បាប់

- ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- ច្បាប់រៀបចំអង្គការ
- កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (២០១០-២០១៩)
- ផែនការអនុវត្តរយៈពេលបីឆ្នាំដំបូង (២០១១-២០១៣)

# ច្បាប់រៀបចំអង្គការ

- **ច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ៖**

  - **<u>មាត្រា២០០</u>** នៃច្បាប់រៀបចំអង្គការតម្រូវថា "**គ.ជ.អ.ប ត្រូវពិនិត្យឡើងវិញនូវការ ទទួលខុសត្រូវ និងមុខងាររបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីកំណត់មុខងារសម្រាប់ផ្ទេរដល់ក្រុមប្រឹក្សានានានៅថ្នាក់ក្រោមជាតិ**"

  - **មាត្រា២១៤៖** ក្រុមប្រឹក្សាប្រភេទនីមួយៗ ត្រូវរួមចំណែកសម្រេចឲ្យបាននូវគោលបំណងរួមនេះ ដោយធ្វើការគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារដែលបានផ្ទេរឲ្យអនុលោមតាមច្បាប់នេះប្រកបដោយប្រសិទ្ធភាព



- មាត្រា២១៥ ដល់មាត្រា២២១៖ **<u>ការពិនិត្យមើលមុខងារឡើងវិញ</u>**ដើម្បី **<u>កំណត់ពីមុខងារណាខ្លះដែលត្រូវផ្ទេរទៅឲ្យដល់រដ្ឋបាលរាជធានី ខេត្ត ស្រុក ក្រុង ខណ្ឌ</u>**
- មាត្រា២៣៣ ដល់មាត្រា២៤០ ៖**<u>ដំណើរការផ្ទេរមុខងារជាកាតព្វកិច្ច ឬជាជម្រើស តាមរយៈការប្រគល់ ឬការធ្វើប្រតិភូកម្ម និងការផ្ទេរធនធានពីក្រសួង ស្ថាប័ននានា ទៅឲ្យដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ</u>**។
- ច្បាប់រៀបចំអង្គការ កំណត់អំពីគោលការណ៍ដែលត្រូវគោរព និងការទទួលខុសត្រូវដល់ គ.ជ.អ.ប ពាក់ព័ន្ធនឹងការកំណត់ និងការផ្ទេរមុខងារទាំងនោះ
- **<u>អនុគណៈកម្មាធិការមុខងារ និងធនធាន ត្រូវបានបង្កើតឡើងដើម្បីជួយ គ.ជ.អ.ប ក្នុងការគ្រប់គ្រង និងចាត់ចែងដំណើរការផ្ទេរមុខងារ</u>**។

## ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

- **<u>មាត្រា ៤៤</u> ៖** "ការផ្ទេរប្រតិភូកម្មអំណាចរបស់រដ្ឋទៅឲ្យរដ្ឋបាលឃុំ សង្កាត់ ដោយមានភ្ជាប់ជាមួយនូវការបង្កើនសមត្ថភាព និងការផ្គត់ផ្គង់មធ្យោបាយ សម្ភារៈ និងថវិកាសម្រាប់អនុវត្ត។"



## កម្មវិធីជាតិ

- សមាសធាតុកម្មវិធីទី៣៖
  - មានគោលបំណង<u>**លើកកម្ពស់បរិមាណ**</u> និង<u>**គុណភាពនៃការផ្តល់សេវាសាធារណៈ**</u> តាមរយៈ<u>**ការផ្ទេរមុខងារ**</u>ឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយ**ភ្ជាប់ជាមួយ**នូវការ<u>**ទទួលខុសត្រូវ**</u> <u>**សិទ្ធិអំណាច**</u> និង<u>**ធនធាន**</u> ដែលពាក់ព័ន្ធនឹង**ការអនុវត្តមុខងារទាំងនោះ**
  - **ធានាថា** ការផ្ទេរមុខងាររួមទាំងការ**ផ្ទេរធនធាន** សិទ្ធិអំណាច និងការទទួលខុសត្រូវ **ត្រូវបានធ្វើឡើង**ដោយមាន**ភាពជាដៃគូជាមួយក្រសួង ស្ថាប័ន** ព្រមទាំង**ផ្អែកលើវិធីសាស្ត្រដែលមានលក្ខណៈជាប្រព័ន្ធ** និង**ទាន់ពេលវេលា**។

## ផែនការអនុវត្តរយៈពេលបីឆ្នាំដំបូង (ផអ៣)

- **ការផ្ទេរមុខងារ និងធនធានទៅរដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាគោលដៅចម្បងសម្រាប់ ផអ៣**
- ដំណើរការផ្ទេរមុខងារត្រូវរៀបចំឡើងដោយ**តម្លាភាព** និងមានការឯកភាពពីអ្នកពាក់ព័ន្ធទាំងអស់
- ដំណើរការផ្ទេរមុខងារ ត្រូវធ្វើឡើង**ជាដំណាក់កាល មានការសាកល្បង មានផែនការច្បាស់លាស់ និងមានការប្រយ័ត្នប្រយែង** ( ឧទា. នៅឆ្នាំទី២ ឆ្នាំទី៣ នៃផអ៣ ចាប់ផ្តើមសាកល្បងផ្ទេរមុខងារណាខ្លះ )



# II - ខ្លឹមសារអនុក្រឹត្យ

## ១. គោលបំណងនៃការរៀបចំអនុក្រឹត្យ

- **ជានានូវការផ្ទេរមុខងារ និងធនធាន**នានាពីក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយមាន**លក្ខណៈជាប្រព័ន្ធ អាចគ្រប់គ្រងបាន តាមដំណាក់កាល មានសនិទានភាព ការសម្របសម្រួល ការពិគ្រោះយោបល់ តម្លាភាព ប្រកបដោយសមធម៌ និងមានការចូលរួមពីក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលទាំងមូល។**

- ដើម្បីកំណត់ពីគោលការណ៍ និងពេលវេលាសម្រាប់ការផ្ទេរមុខងារ និងធនធាន និងសម្រាប់ជាមូលដ្ឋានក្នុងដំណើរការផ្ទេរមុខងារ និងធនធន ដោយចាប់ផ្តើមពី**វិស័យ ឬកិច្ចការអាទិភាពមួយចំនួន** ដូចជា៖កសិកម្ម, អប់រំ, ព្រៃឈើ ជលផល ធនធានធម្មជាតិ និងបរិស្ថាន, សុខាភិបាល អាហារូបត្ថម្ភ និងសេវាប្រជាជន រួមទាំងតម្រូវការផ្សេងៗរបស់ស្ត្រី បុរស យុវវ័យ កុមារ ជនងាយរងគ្រោះ និងជនជាតិដើមភាគតិច, ឧស្សាហកម្ម និងការគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ច, ការប្រើប្រាស់ដីធ្លី, ការងារសុរិយោដីនិងការងារសំណង់ ការផលិតនិងចែកចាយអគ្គិសនី, ការគ្រប់គ្រងទឹក ...។ល។



- ដើម្បីកំណត់ពីនីតិវិធីនៃការផ្ទេរមុខងារ ធនធាន និងទ្រព្យសម្បត្តិ ដែលប្រព្រឹត្តទៅតាមដំណាក់កាលៗ មានការប្រយ័ត្នប្រយែងខ្ពស់ ដោយមាន គ.ជ.អ.ប អនុគណៈកម្មាធិការមុខងារ និងធនធាន ជាអ្នកសម្របសម្រួល និងត្រួតពិនិត្យ ព្រមទាំងបើកផ្លូវឲ្យមាន**ដំណើរការបី**ទៅតាមដំណាក់កាលៗគឺ៖
  - **ដំណើរការរៀបចំបញ្ជីវិភាគមុខងារ** សម្រាប់ក្រសួង ស្ថាប័នដែលស្ថិតនៅក្នុងវិស័យ ឬកិច្ចការអាទិភាព ដោយគ្រោង**បញ្ចប់នៅត្រីមាសទី៣ ឆ្នាំ ២០១២**
  - **ដំណើរការពិនិត្យមើលមុខងារឡើងវិញ** សម្រាប់ក្រសួង ស្ថាប័ន ដែលបានរៀបចំបញ្ជីវិភាគមុខងាររួចហើយ ដោយគ្រោង**បញ្ចប់នៅចុងឆ្នាំ ២០១២ និង**
  - **ការសាកល្បងផ្ទេរមុខងារ និងធនធាន** ដោយគ្រោង**ចាប់ផ្តើមនៅចុងឆ្នាំ ២០១២ ឬ នៅដើមឆ្នាំ ២០១៣**

## ២. អនុក្រឹត្យនេះ ត្រូវបានរៀបចំឡើងជា៤ ជំពូក និងមាន៣៨ មាត្រា

- ជំពូកទី១ ៖ បទប្បញ្ញត្តិទូទៅ មាន៤មាត្រា
- ជំពូកទី២ ៖ ដំណើរការផ្ទេរមុខងារ មាន៧ ផ្នែក និងមាន២៧មាត្រា
- ជំពូកទី៣ ៖ អន្តរប្បញ្ញត្តិ មាន២ផ្នែក និងមាន៥មាត្រា
- ជំពូកទី៤ ៖ អវសានប្បញ្ញត្តិ មាន២មាត្រា



## ជំពូកទី១ ៖ បទប្បញ្ញត្តិទូទៅ

**មាន៤មាត្រា ចែងពី៖**

- គោលបំណងដើម្បីធានាបាននូវការផ្ទេរមុខងារស្របតាមច្បាប់រៀបចំអង្គការ
- គោលដៅកំណត់កិច្ចដំណើរការទូទៅ និងពេលវេលានៃការរៀបចំផ្ទេរមុខងារ និងធនធានទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ
- វិសាលភាពអនុវត្តចំពោះការផ្ទេរមុខងារនិងធនធាន
- និយមន័យនៃវាក្យសព្ទបច្ចេកទេសដែលប្រើនៅក្នុងអនុក្រឹត្យ

## ជំពូក ២ ៖ ដំណើរការទូទៅនៃផ្ទេរមុខងារនិងធនធាន

**គោលការណ៍**

- ការផ្ទេរមុខងារនិងធនធាន ត្រូវធ្វើឡើងជាដំណាក់កាល មានសនិទានភាព លក្ខណៈ ជាប្រព័ន្ធ ការសម្របសម្រួល ការពិគ្រោះយោបល់ ផែនការ តម្លាភាព និងប្រកបដោយ សមធម៌
- ការផ្ទេរមុខងារ និងធនធាន ត្រូវផ្តល់អាទិភាពចំពោះកិច្ចការចាំបាច់ ដែលជះឥទ្ធិពលដោយផ្ទាល់ដល់ការកាត់បន្ថយភាពក្រីក្រ ការកែលម្អគុណភាពនៃជីវភាពរស់នៅរបស់ប្រជាជន និងការអភិវឌ្ឍមូលដ្ឋាន



## ជំពូក ២ ៖ ដំណើរការទូទៅនៃផ្ទេរមុខងារនិងធនធាន

**គោលការណ៍ (ត)**

- គោលការណ៍ដែលត្រូវគោរពតាមក្នុងដំណើរការផ្ទេរមុខងារ តាមរយៈការប្រគល់ ឬការធ្វើប្រតិភូកម្ម
- តួនាទីរបស់គ.ជ.អ.ប ក្នុងការពិនិត្យឡើងវិញនូវការទទួលខុសត្រូវ និងមុខងាររបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព និងអាជ្ញាធរ ដើម្បីកំណត់មុខងារ និងធនធានសម្រាប់ផ្ទេរ
- តួនាទីសម្របសម្រួល គាំទ្រ និងតាមដានរបស់ គ.ជ.អ.ប អនុគណៈកម្មាធិការមុខងារ និងធនធាន និងលេខាធិការរបស់ខ្លួន ក្នុងដំណើរការផ្ទេរមុខងារ និងធនធាន

# ការរៀបចំបញ្ជីវិភាគមុខងារ

- ការរៀបចំបញ្ជីវិភាគមុខងាររបស់ក្រសួង ស្ថាប័ន ដើម្បីកំណត់ពី៖
  - ✓ មុខងារទាំងអស់ដែលកំពុងអនុវត្តជាក់ស្តែង និងអង្គភាពដែលគ្រប់គ្រង និងទទួលខុសត្រូវលើការអនុវត្តមុខងារទាំងនេះ
  - ✓ ក្របខ័ណ្ឌច្បាប់ជាមូលដ្ឋានសម្រាប់បំពេញមុខងារទាំងនេះ
  - ✓ ធនធានហិរញ្ញវត្ថុជាក់ស្តែងនាពេលបច្ចុប្បន្នដែលបានប្រើប្រាស់ដើម្បីអនុវត្តមុខងារទាំងនេះ
  - ✓ ធនធានមនុស្សជាក់ស្តែងនាពេលបច្ចុប្បន្នដែលទទួលខុសត្រូវក្នុងការអនុវត្តមុខងារទាំងនេះ
  - ✓ មធ្យោបាយ សម្ភារៈ បរិក្ខារ និងធនធានផ្សេងទៀតដែលចាំបាច់សម្រាប់អនុវត្តមុខងារ



- សេចក្តីណែនាំស្តីពីការរៀបចំបញ្ជីវិភាគមុខងារ ដែលត្រូវរៀបចំដោយ គ.ជ.អ.ប ដើម្បីធ្វើជាមូលដ្ឋានក្នុងការរៀបចំបញ្ជីវិភាគមុខងារ
- បន្ទាប់ពីរៀបចំបញ្ជីវិភាគមុខងាររួច ក្រសួង ស្ថាប័ន ត្រូវផ្ញើរបាយការណ៍មកគ.ជ.អ.ប ដើម្បីពិនិត្យ និងសម្រេច

# ការពិនិត្យមើលមុខងារឡើងវិញ

- ការពិនិត្យមើលឡើងវិញនូវមុខងារ ធនធាន លិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធ និងការទទួលខុសត្រូវក្នុងការអនុវត្តមុខងារ ដើម្បីកំណត់មុខងារ និងធនធានដែលត្រូវផ្ទេរ
- លក្ខខណ្ឌនៃការពិនិត្យមើលឡើងវិញនូវមុខងារ
- ការធានាឲ្យមានសង្គតិភាពក្នុងការពិនិត្យមើល មុខងារឡើងវិញក្នុងវិស័យទាំងឡាយណាដែលមានការពាក់ព័ន្ធនឹងក្រសួង ស្ថាប័នលើសពីមួយ



- ការពិនិត្យមើលមុខងារឡើងវិញត្រូវកំណត់ផងដែរពីធនធានដែលត្រូវផ្ទេរជាមួយមុខងារ ព្រមជាមួយនឹងផែនការអភិវឌ្ឍសមត្ថភាព ដើម្បីធានាដល់ការចាត់ចែង ការគ្រប់គ្រង និងការអនុវត្ត
- ការកំណត់អំពីតួនាទី និងការទទួលខុសត្រូវថ្មីរបស់ក្រសួង ស្ថាប័ន បន្ទាប់ពីមុខងារត្រូវបានផ្ទេរ
- សេចក្តីណែនាំស្តីពីការពិនិត្យមើលមុខងារឡើងវិញដែលរៀបចំដោយ គ.ជ.អ.ប សម្រាប់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ធ្វើជាមូលដ្ឋានក្នុងការពិនិត្យមើលមុខងារឡើងវិញរបស់ខ្លួន
- បន្ទាប់ពីបានពិនិត្យមើលឡើងវិញនូវមុខងាររួច ក្រសួង ស្ថាប័ន ត្រូវផ្ញើរបាយការណ៍មក គ.ជ.អ.ប ដើម្បីពិនិត្យ និងសម្រេច

## ការអភិវឌ្ឍសមត្ថភាព

- ការកសាងសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារ និងធនធាន ក្នុងពេលវេលាមួយសមស្រប តាមរយៈការរៀបចំផែនការអភិវឌ្ឍន៍សមត្ថភាព ដោយមានកិច្ចសហការជាមួយក្រុមប្រឹក្សា មន្ត្រីថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានា



## ការផ្ទេរមុខងារ ធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ

- ការផ្ទេរនិងការធ្វើប្រតិភូកម្មមុខងារ ត្រូវធ្វើឡើងដោយច្បាប់ ឬព្រះរាជក្រឹត្យ ឬអនុក្រឹត្យ ឬប្រកាស ឬលិខិតបទដ្ឋានគតិយុត្តិផ្សេងៗទៀត(មាត្រា២៣៣ ដល់មាត្រា២៤០នៃច្បាប់អង្គការ)
- ការផ្ទេរធនធានហិរញ្ញវត្ថុ ត្រូវធ្វើឡើងស្របតាមបញ្ញត្តិដូចមានចែងក្នុងជំពូកទី៥ផ្នែកទី៦នៃច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងជំពូកទី៣ ផ្នែកទី២ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ការផ្ទេរទ្រព្យសម្បត្តិ ត្រូវធ្វើឡើងស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងជំពូកទី៥ ផ្នែកទី៧នៃច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងជំពូកទី៤ ផ្នែកទី២ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

# ការផ្ទេរមុខងារ ធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ

- ការធានាឲ្យមានភាពសមស្របរវាងសេចក្តីព្រាងលិខិតបទដ្ឋានគតិ-យុត្តជាមួយច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ និង អនុក្រឹត្យនេះ
- វិស័យនិងមុខងារទាំងឡាយដែលត្រូវលើកលែងចំពោះការផ្ទេរទៅឲ្យឃុំ សង្កាត់ *(មាត្រា៤៥ ច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់)*៖
  - ព្រៃឈើ ប្រៃសណីយ៍និងទូរគមនាគមន៍
  - ការការពារជាតិ សន្តិសុខជាតិ នយោបាយក្រៅប្រទេស
  - រូបិយវត្ថុ គោលនយោបាយសារពើពន្ធ
  - និងវិស័យផ្សេងទៀត ដែលមានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធ



- ដំណើរការ និងនីតិវិធីនៃការផ្ទេរធនធានហិរញ្ញវត្ថុ សម្រាប់អនុវត្តមុខងារដែលនឹងត្រូវផ្ទេរត្រូវកំណត់ដោយច្បាប់ ឬព្រះរាជក្រឹត្យ ឬ អនុក្រឹត្យ ឬប្រកាសស្តីពីការផ្ទេរមុខងារ

## ស្ថាប័នទទួលបន្ទុកអនុវត្ត

### ១. គ.ជ.អ.ប

- ទទួលខុសត្រូវរួមលើដំណើរការពិនិត្យមើលឡើងវិញនូវមុខងារ និងដំណើរការផ្ទេរមុខងារ និងធនធានស្របតាមច្បាប់គ្រប់គ្រងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាលស្តីពីវឌ្ឍនភាពនៃដំណើរការពិនិត្យមើលឡើងវិញនូវមុខងារ និងការផ្ទេរមុខងារនិងធនធាន

### ២. ក្រសួង ស្ថាប័ន

- ធ្វើរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តការផ្ទេរមុខងារ និងធនធានរបស់ខ្លួនជូន គ.ជ.អ.ប
- ទទួលខុសត្រូវជាចម្បងចំពោះមុខគ.ជ.អ.ប លើដំណើរការរៀបចំបញ្ជីវិភាគមុខងារ ការពិនិត្យមើលឡើងវិញនូវមុខងារ និងដំណើរការផ្ទេរមុខងារ និងធនធាន



## ស្ថាប័នទទួលបន្ទុកអនុវត្ត

### ៣. រដ្ឋបាលថ្នាក់ក្រោមជាតិ

- ទទួលខុសត្រូវក្នុងការរួមចំណែកជួយគាំទ្រដល់ដំណើរការពិនិត្យមើលឡើងវិញនូវមុខងារដែលត្រូវផ្ទេរទៅឲ្យរដ្ឋបាលរបស់ខ្លួន
- រដ្ឋបាលរាជធានី និងរដ្ឋបាលក្រុង ត្រូវពិនិត្យមើលមុខងាររបស់ខ្លួនឡើងវិញ ស្របតាមគោលការណ៍ដែលមានចែងក្នុងមាត្រា៥ មាត្រា៦ និងមាត្រា៧នៃអនុក្រឹត្យនេះ

## យន្តការនាំមុខ

**១. គ.ជ.អ.ប**

ត្រូវជានាយកថា ការផ្ទេរមុខងារនិងធនធានត្រូវធ្វើឡើងតាមលក្ខណៈជាប្រព័ន្ធ តាមដំណាក់កាល មានសង្គតិភាព ការសម្របសម្រួល ការពិគ្រោះយោបល់ តម្លាភាព និងប្រកបដោយសមធម៌

**២. អនុគណៈកម្មាធិការមុខងារ និងធនធាន**

ជួយលើការងារសម្របសម្រួល ពិគ្រោះយោបល់ ព្រមទាំងផ្តល់អនុសាសន៍ជូនគ.ជ.អ.បលើការងារទាំងអស់ពាក់ព័ន្ធនឹងភារកិច្ច និងការទទួលខុសត្រូវក្នុងការកំណត់និងការផ្ទេរមុខងារនិងធនធានដល់រដ្ឋបាលថ្នាក់ក្រោមជាតិ

**៣. លេខាធិការដ្ឋានគ.ជ.អ.ប**

ទទួលខុសត្រូវជួយអនុគណៈកម្មាធិការមុខងារនិងធនធាន និងគ.ជ.អ.ប ផ្នែកបច្ចេកទេស ការសម្របសម្រួល ការពិគ្រោះយោបល់ ព្រមទាំងការគាំទ្រផ្នែកហិរញ្ញវត្ថុដល់ដំណើរការផ្ទេរមុខងារនេះ។



## ជំពូកទី៣:ដំណើរការផ្ទេរមុខងារនិងធនធានសម្រាប់វិស័យឬកិច្ចការអាទិភាព

- វិស័យ ឬកិច្ចការអាទិភាពដែលត្រូវអាទិភាព(២០១២-២០១៣)រួមមានៈ
  - ✓ កសិកម្ម, អប់រំ, ព្រៃឈើ ជលផល ធនធានធម្មជាតិ និងបរិស្ថាន,
  - ✓ សុខាភិបាល អាហារូបត្ថម្ភ និងសេវាប្រជាជន រួមទាំងតម្រូវការផ្សេងៗរបស់ស្ត្រី បុរស យុវវ័យ កុមារ ជនងាយរងគ្រោះ និងជនជាតិដើមភាគតិច,
  - ✓ ឧស្សាហកម្ម និងការគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ច, ការប្រើប្រាស់ដីធ្លី, ការផលិត និងចែកចាយអគ្គិសនី, ការគ្រប់គ្រងទឹក

## ជំពូកទី៣:ដំណើរការផ្ទេរមុខងារនិងធនធានសម្រាប់វិស័យឬកិច្ចការអាទិភាព

- ✓ តម្រូវការពិសេស ឬ តម្រូវការដែលបានកំណត់ជាក់លាក់សម្រាប់ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដោយគិតទាំងវិស័យ ទេសចរណ៍ តំបន់ប្រវត្តិសាស្ត្រ និងកេរដំណែល វប្បធម៌ផងដែរ,
- ✓ សង្គមកិច្ច និងអភិវឌ្ឍន៍ជនបទ
- ✓ និងយកចិត្តទុកដាក់ ផ្តល់ការគាំទ្រអំពីហេដ្ឋារចនាសម្ព័ន្ធ មធ្យោបាយ និងសម្ភារៈចាំបាច់ដើម្បីចាត់ចែងការទទួលខុសត្រូវលើ មុខងារដែលបានប្រគល់ និងធ្វើប្រតិភូកម្មទាំងនេះ។



## ពេលវេលានៃការរៀបចំនិងការផ្ទេរមុខងារ

**១. ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ដែលស្ថិតនៅក្នុងចំណោម វិស័យ ឬកិច្ចការអាទិភាព**

- ✓ ត្រូវបញ្ចប់ការធ្វើបញ្ជីវិភាគមុខងារ និងពិនិត្យមើលមុខងារឡើងវិញ និងដាក់របាយការណ៍ជូន គ.ជ.អ.ប ដើម្បី ពិនិត្យ សម្រេចយ៉ាងយូរចុងឆ្នាំ២០១២
- ✓ ត្រូវអនុវត្តដំណើរការផ្ទេរមុខងារ ដោយភ្ជាប់ជាមួយការផ្ទេរធនធានហិរញ្ញវត្ថុ ធនធានមនុស្ស និងធនធាន ផ្សេងទៀតដែលចាំបាច់ និងសមស្របទៅតាមដំណាក់កាលៗយ៉ាងយូរនៅក្នុងឆ្នាំ២០១៣

**២. ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់មិនស្ថិតនៅក្នុងចំណោមវិស័យ ឬកិច្ចការអាទិភាព**

- ✓ ត្រូវអនុវត្តទៅតាមដំណើរការរៀបចំបញ្ជីវិភាគមុខងារ និងការពិនិត្យមើលឡើងវិញនូវមុខងារ និងដាក់របាយការណ៍ជូន គ.ជ.អ.ប ដើម្បីពិនិត្យ សម្រេច យ៉ាងយូរនៅក្នុងឆ្នាំ ២០១៣

❖ **ពេលវេលា ដំណាក់កាលនីមួយៗ និងក្រសួង ស្ថាប័ន មន្ទីរ អង្គភាព និអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដែលត្រូវចាប់ផ្តើមអនុវត្តដំណើរការផ្ទេរ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់គ.ជ.អ.ប**

## ការផ្ទេរធនធានមនុស្ស

- ក្នុងអំឡុងពេលមិនទាន់មានច្បាប់ ឬបទប្បញ្ញត្តិស្ដីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិកនៅថ្នាក់ក្រោមជាតិ ដំណើរការ និងនីតិវិធីនៃការផ្ទេរធនធានមនុស្សសម្រាប់អនុវត្តមុខងារ ត្រូវកំនត់ដោយច្បាប់ ឬព្រះរាជក្រឹត្យ ឬអនុក្រឹត្យ ឬប្រកាស



# សូមអរគុណ